មើលវីដេអូ ចេតសិកនិងចិត្ត ភាគទី ៤

# ៣- សញ្ញាចេតសិក (Perception)

នីលាទិភេទារម្មណំ សញ្ជានាតិ សញ្ញំ កត្វា ជានាតីតិ = សញ្ញា

ធម្មជាតិដែលឈ្មោះថា សញ្ញា ព្រោះសេចក្ដីថា ចងចាំអារម្មណ៍ផ្សេងៗ មានពណ៌ខៀវជាដើម គឺធ្វើនូវការកំណត់សំគាល់(ឬចំណាំ)។

ស្កេនដើម្បីមើលមេរៀន

San Sochea Official

# លក្ខណាទិចតុក្កៈរបស់សញ្ញាចេតសិក

១- សញ្ជាននលក្ខណា មានការចងចាំ (ឬ សម្គាល់) ជាលក្ខណៈ

២- បុនសញ្ជាននបច្ចយនិមិត្តករណរសា មានការស្គាល់ និងធ្វើនូវការសម្គាល់ទុកជាកិច្ច (*ដូចជាងឈើធ្វើនូវសញ្ញាសម្គាល់ត្រង់ដើមឈើជាដើម*)

៣- យថាគហិតនិមិត្តវសេន អភិនិវេសករណបច្ចុប្បដ្ឋានាមានការអាស្រ័យនូវនិមិត្តតាមដែលបានកំណត់ទុក (ឬចាំបាន) ជាអាការប្រាកដ

៤- យថាឧបដ្ឋិតវិសយបទដ្ឋានា មានអារម្មណ៍ដែលប្រាកដ ជាហេតុជិត។

# ៤ - ចេតនាចេតសិក (Volition)

ចេតនាចេតសិក ជាធម្មជាតិផ្គងចិត្ត គឺចាត់ចែងដាស់តឿនសម្បយុត្តធម៌ដែលកើតព្រមជាមួយនឹងខ្លួន ឱ្យធ្វើកិច្ចរបស់ខ្លួន។

ចេតេតិ អត្តនា សម្បយុត្តធម្មេ អារម្មណេ អភិសន្ទហតិ សង្ខតាភិសង្ខរណេ វា ព្យាបារមាបជ្ជតីតិ = ចេតនា ធម្មជាតិដែលឈ្មោះថា ចេតនា ព្រោះអត្ថថា តាំងចិត្ត គឺ ញ៉ាំងសម្បយុត្តធម៌ ឲ្យព្រមព្រៀងជាមួយនឹងខ្លួនក្នុងអារម្មណ៍ ឬ ដែលឈ្មោះថា ចេតនា ព្រោះអត្ថថា ដល់នូវសេចក្ដីខ្វល់ខ្វាយក្នុងការតាក់តែងធម៌ដែលជាសង្ខតៈ។

# លក្ខណាទិចតុក្កៈរបស់ចេតនា

| | |
|---|---|
| ១. ចេតនាភាវលក្ខណា | មានការផ្គងចិត្ត ជាលក្ខណៈ |
| ២. អាយូហនរសា | មានការប្រមូលមក ជាកិច្ច |
| ៣. សំវិធានបច្ចុប្បដ្ឋានា | មានការចាត់ចែង ជាអាការប្រាកដ (ដូចជាងឈើធ្វើកិច្ចឱ្យសម្រេច) |
| ៤. សេសខន្ធត្ថយបទដ្ឋានា | មានខន្ធ ៣ ដែលនៅសល់ (វេទនា សញ្ញា វិញ្ញាណ) ជាហេតុជិត។ |